**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៤៨ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៩, ចុះថ្ងៃ ទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ , ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone . 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ដែលចែកជាចំណាត់ថ្នាក់ចំណូល និងចំណាត់ថ្នាក់ចំណាយ និងត្រូវបានបែងចែកជា ក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ ២ :** ប្រកាសលេខ ១៤០១ សហវ-ប្រក . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០៨ តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | | **សរុបរួមចំណូលថវិការបស់រដ្ឋ (ក+ខ)** | សរុបចំណូលជាប្រក្រតី និង សរុបចំណូលជាមូលធន ។ |
| | | | **ក.សរុបចំណូលចរន្ត (ក្រុមទី១+ក្រុមទី២)** | ចំណូលដែលត្រូវប្រមូលជាប្រចាំ ។ ចំណូលនេះរួមមានចំណូលពិត និង ចំណូលតាមបញ្ជិកា ។ |
| | | | **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | ចំណូលជាសាច់ប្រាក់ជាក់ស្តែង ។ ចំណូលនេះរួមមានចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ។ |
| | | | **ប្រភេទទី១: ចំណូលសារពើពន្ធ** | ចំណូលសារពើពន្ធគឺជាពន្ធ អាករ និង សិទ្ធដែលត្រូវ បានបង់ជាកាតព្វកិច្ចទៅអោយរដ្ឋ ។ ចំណូលនេះរួមមាន : ចំណូលសារពើពន្ធក្នុងប្រទេស និង ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ។ |
| 70 | | | ចំណូលសារពើពន្ធក្នុងប្រទេស | កត់ត្រាចំណូលទទួលបានពីពន្ធដារ និង ពន្ធគយក្នុងប្រទេស |
| | 700 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (រូបវ័ន្តបុគ្គល) | ចំណូលមកពីការបង់ពន្ធលើផលទុន ប្រាក់ចំណេញ និង កំរៃទុន ដោយរូបវ័ន្តបុគ្គល |
| | | 7001 | ពន្ធលើប្រាក់បៀវត្ស | ចំណូលបានមកពីការបង់ពន្ធប្រាក់បៀវត្សដោយបុគ្គលិករដ្ឋ ឬ ឯកជន ដែលជាប់កាតព្វកិច្ចបង់ពន្ធ |
| | | 7002 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | ចំណូលបានមកពីការបង់ពន្ធលើផលទុននៃដីធ្លី ផ្ទះសំបែង |
| | | 7003 | ពន្ធលើផលចំណេញពីការលក់អចលនទ្រព្យ | ចំណូលបានមកពីការបង់ពន្ធលើផលចំណេញពីការលក់ដីធ្លី ការលក់អាគារ និង ផ្ទះសំបែង........... |
| | 701 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (នីតិបុគ្គល) | ចំណូលមកពីការបង់ពន្ធលើផលទុន ប្រាក់ចំណេញ និង កំរៃទុន ដោយនីតិបុគ្គល |
| | | 7011 | ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | ចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ ដូចជាពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនចំការកៅស៊ូ កំពង់ផែកំពង់សោម ..... |
| | | 7012 | ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន | ចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសឯកជន ដូចជាពន្ធលើប្រាក់ចំណេញ របស់ក្រុមហ៊ុននាំចេញ-នាំចូល.......... |
| | | 7013 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | ចំណូលបានមកពីការបង់ពន្ធលើផលទុននៃដីធ្លី ផ្ទះសំបែង |
| | | 7014 | ពន្ធលើផលចំណេញពីការលក់អចលនទ្រព្យ | ចំណូលបានមកពីការបង់ពន្ធលើផលចំណេញពីការលក់ដីធ្លី ការលក់អាគារ និង ផ្ទះសំបែង...... |
| | 702 | | ពន្ធទូទៅលើទ្រព្យសម្បត្តិ និងសេវា | ចំណូលទទួលបានពីការបង់អាករលើផលរបរ និង អាករលើតំលៃបន្ថែម ។ អាករនេះ អាចត្រូវបានប្រមូលគ្រប់រូបភាពនៃដំណើរផលិតកម្ម ការចែកចាយទំនិញ ឬ សេវា ដែលផលិតនៅក្នុងប្រទេស ឬ នាំចូលពីបរទេស ។ |
| | | 7021 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសសាធារណៈ) | ចំណូលបានមកពីការបង់អាករលើផលរបរសរុបរបស់សហគ្រាសសាធារណៈក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មផ្សេងៗក្នុងប្រទេស |
| | | 7022 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសឯកជន) | ចំណូលបានមកពីការបង់អាករលើផលរបរសរុបរបស់សហគ្រាសឯកជនក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មផ្សេងៗក្នុងប្រទេស |
| | | 7023 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសសាធារណៈ) | ចំណូលបានមកពីការបង់អាករបន្ថែមលើតំលៃទំនិញ ឬសេវាកម្មផ្សេងៗដោយសហគ្រាសសាធារណៈដែលផលិតទំនិញ ឬចែកចាយទំនិញ និង សេវាកម្មទាំងនោះនៅក្នុងប្រទេស |

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 7052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | ចំណូលបានមកពីការផ្តល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ដូចជា អាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ អាជ្ញាប័ណ្ណកាំបូលិច អាជ្ញាប័ណ្ណឆ្នោត អាជ្ញាប័ណ្ណទេសចរណ៍........។ អនុគណនីនេះកត់ត្រាផងដែរ នូវពន្ធដែលបង់ដោយអ្នកធ្វើសម្បទានដែលជាអ្នកធ្វើវិនិយោគដោយខ្លួនឯង ។ |
| | 708 | | ចំណូលសារពើពន្ធផ្សេងៗទៀត | ចំណូលទទួលបានពីពន្ធតែមប្រ៍ និង ចំណូលបានមកពីការពិន័យលើភាពយឺតយ៉ាវ និង កំហុសនៃការបង់ពន្ធ |
| | | 7081 | ពន្ធតែមប្រ៍ | ចំណូលបានមកពីការបង់ពន្ធតែមប្រ៍តាមកិច្ចសន្យា |
| | | 7082 | ការដាក់ពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | ចំណូលបានមកពីការពិន័យលើភាពយឺតយ៉ាវ និង កំហុសនៃការបង់ពន្ធ |
| **71** | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | **កត់ត្រាចំណូលទទួលបានពីការបង់ពន្ធ និង អាករ លើការនាំចូល និងការនាំចេញ** |
| | 710 | | ពន្ធ និងអាករលើការនាំចូល | ចំណូលទទួលបានពីការបង់ពន្ធ និង អាករលើការនាំចូល |
| | | 7101 | ពន្ធគយពីការនាំចូល | ចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលទំនិញផ្សេងៗលើកលែងតែការនាំចូលប្រេងឥន្ធនៈ |
| | | 7102 | កំរៃយកមុនពីការងារគយក្នុងការនាំចូល | ចំណូលទទួលបានពីការយកកំរៃផ្សេងៗក្នុងការនាំចូល ដូចជា ការនាំចូលទំនិញសំរាប់លក់ក្នុងអាគារលក់ទំនិញរួចពន្ធ ការនាំចូលទំនិញឆ្លងកាត់ ការនាំចូលទំនិញដោយមិនបានឆ្លងយន្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុក ការស្តុកទំនិញក្នុងឃ្លាំង ឬទីលានហួសកាលកំណត់ និង កំរៃផ្សេងៗទៀតដែលពុំមែនជាពន្ធ ឬ អាករ |
| | | | -កំរៃលើទំនិញនៃអាគារលក់ទំនិញរួចពន្ធ | |
| | | | -កំរៃឆ្លងកាត់ | |
| | | | -កំរៃផ្សេងៗលើការងារគយក្នុងការនាំចូល | |
| | | 7103 | ពន្ធគយលើផលិតផលគេលសិលា | ចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលប្រេងឥន្ធនៈ |
| | | 7104 | អាករបន្ថែមលើផលិតផលគេលសិលាសំរាប់ថែទាំផ្លូវថ្នល់ | ចំណូលទទួលបានពីការបង់អាករបន្ថែមលើតំលៃប្រេងឥន្ធនៈនាំចូល ហើយ ចំណូលនេះប្រើប្រាស់ សំរាប់ថែទាំផ្លូវថ្នល់ |
| | | 7105 | ផលនៃការលក់ផ្ញើគយ | ចំណូលទទួលបានពីការលក់ផលិតផលផ្សេងៗដែលភ្នាក់ងារគយរឹបអូសបានពីការនាំចូលខុសច្បាប់ ការរត់គេចពន្ធ............ |
| | | 7106 | ពិន័យផ្សេងៗលើការនាំចូល | ចំណូលទទួលបានពីការបង់ពិន័យផ្សេងៗលើការនាំចូល |
| | 711 | | ពន្ធ និង អាករលើការនាំចេញ | ចំណូលទទួលបានពីការបង់ពន្ធ និង អាករលើការនាំចេញ |
| | | 7111 | អាករលើការនាំចេញឈើ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញឈើគ្រប់ប្រភេទ |
| | | 7112 | អាករលើការនាំចេញកៅស៊ូ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញកៅស៊ូ |
| | | 7113 | អាករលើការនាំចេញផលិតផលគេលសិលា | ចំណូលទទួលបានពីការបង់អាករលើការនាំចេញផលិតផលគេលសិលា |
| | | 7114 | អាករលើការនាំចេញផលិតផល និងកសិផលផ្សេងៗ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញផលិតផល និង កសិផលផ្សេងៗ ក្រៅពីឈើ កៅស៊ូ និង ផលិតផលគេលសិលា |
| | | 7115 | កំរៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ចំណូលទទួលបានពីការផ្តល់កូតា និង អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ស្បែកជើង...... |
| | | 7116 | ពិន័យផ្សេងៗលើការនាំចេញ | ចំណូលទទួលបានពីការពិន័យផ្សេងៗលើការនាំចេញដែលមិនគោរពតាមបទដ្ឋាន |

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 7118 | ពន្ធ និងអាករលើការនាំចេញផ្សេងៗ | ចំណូលទទួលបានពីការបង់ពន្ធ និង អាករលើការនាំចេញផ្សេងទៀតក្រៅពីអនុគណនី ០៦ ខាងលើ |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | **ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម ការឧបត្ថម្ភ អំណោយ ផលហិរញ្ញវត្ថុ និងផលផ្សេងៗ និងផលពិសេស** |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ចំណូលទទួលបានពីការជួល និង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ |
| | 720 | | ផលនៃសម្បទាន និងការជួលដីធ្លី | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជាការជួលឡនេសាទ ការជួលដីព្រៃឈើ ការជួលដែនទឹកសំរាប់ធ្វើអាជីវកម្មប្រេងកាត ការជួលដីសំរាប់រុករករ៉ែ និង ការជួលដីធ្លីផ្សេងៗទៀត |
| | | 7201 | សម្បទាននេសាទ | ចំណូលទទួលបានពីការជួលឡនេសាទ |
| | | 7202 | សម្បទានព្រៃឈើ | ចំណូលទទួលបានពីការធ្វើសម្បទានព្រៃពេកើ ដូចជា ចំណូលពីការលក់ឈើឈរ អនុផលព្រៃឈើ និង ចំណូលពីការលក់ឈើខុសច្បាប់ដែលរឹបអូសបាន |
| | | 7203 | សម្បទានពីប្រេងកាត | ចំណូលទទួលបានពីការជួលដី ឬ ដែនទឹកដែលមានប្រេងកាត ទៅអោយឯកជនដើម្បីធ្វើអាជីវកម្មបូមប្រេងកាត |
| | | 7204 | សម្បទានរ៉ែ | ចំណូលទទួលបានពីការជួលផ្ទៃដីសំរាប់ដំណាក់កាលសិក្សា ស្រាវជ្រាវស្វែងរុករករ៉ែ និង ជួលដីជីករ៉ែ និង ទីតាំងអាជីវកម្មក្នុងដំណាក់កាលធ្វើអាជីវកម្មរ៉ែ និង ចំណូលទទួលបានពីសួយសារ និង ភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្មរ៉ែ ។ |
| | | | .អាជីវកម្មរ៉ែ | ចំណូលពីអាជីវកម្មរ៉ែ |
| | | | .សួយសារថ្លៃឈ្នួលប្រចាំឆ្នាំ | ចំណូលពីការជួលដីដែលមានរ៉ែ |
| | | | .សួយសារដី | ចំណូលបានពីឈ្នួលដីដែលមិនមានរ៉ែហើយដែលដីនេះត្រូវបានធ្វើសម្បទានដោយរដ្ឋទៅអោយក្រុមហ៊ុនឯកជនសំរាប់បំរើអោយដំណើរការការងារអាជីវកម្មរុករករ៉ែ |
| | | 7205 | ការជួលដីទំនេរ | ចំណូលពីការជួលដីទំនេរ ឬ ដីដែលមានអាគារចាស់ទ្រុឌទ្រោម |
| | | 7208 | ផលនៃការជួលដីធ្លីផ្សេងៗ | ចំណូលពីការជួលដីធ្លីផ្សេងៗទៀតដែលមិនមាននៅក្នុងអនុគណនី៥ខាងលើ ។ |
| | 721 | | ផលទុនពីសហគ្រាសសាធារណៈ | កត់ត្រាចំណូលទទួលបានពីសហគ្រាសសាធារណៈ ដូចជាចំនួនលើសនៃទុនចល័ត ប្រាក់ចំណេញ ការបង់ប្រាក់រំលស់ និង ទុនផ្សេងៗទៀត |
| | | 7211 | ចំនួនលើសនៃទុនចល័ត | ចំណូលទទួលបានពីការបង់មកវិញនូវទុនចល័តដែលលើសពីតំរូវការរបស់សហគ្រាសសាធារណៈ |
| | | 7212 | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | ចំណូលទទួលបានពីការបង់ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ ក្រោយការិយបរិច្ឆេទបិទបញ្ជីប្រចាំឆ្នាំ ដូចជាប្រាក់ចំណេញរបស់ក្រុមហ៊ុនកៅស៊ូកម្ពុជា......... |
| | | 7213 | ការបង់ប្រាក់រំលស់ | ចំណូលទទួលបានពីការបង់ប្រាក់រំលស់របស់សហគ្រាសសាធារណៈ |
| | | 7218 | ផលទុនផ្សេងៗពីសហគ្រាសសាធារណៈ | ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈក្រៅពីអនុគណនី ៣ ខាងលើ ។ |

## ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| 73 | | | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា | កត់ត្រាចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិតូចតាចក្រៅពីដីធ្លី និង អាគារ ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិ និង ចំណូលទទួលបានពីការផ្តល់សេវា ដោយរដ្ឋ ។ |
| | 730 | | សហគ្រាសសាធារណៈ រដ្ឋបាល និងសេវាដំណើរការ ( រកចំណេញ) | ចំណូលទទួលបានពីស្ថាប័នរដ្ឋ និង សហគ្រាសសាធារណៈក្នុងការផ្តល់សេវា និង ការផ្តល់សិទ្ធិ |
| | | 7301 | ផលទុនរបស់អាកាសចរស៊ីវិល | ចំណូលទទួលបានពីប្រតិបត្តិការនៃក្រុមហ៊ុនអាកាសចរនៅកម្ពុជា និង សិទ្ធិនៃការហោះហើរឆ្លងកាត់លំហអាកាសកម្ពុជា |
| | | 7302 | ផលមុននៃសកម្មភាពភាពយន្ត | ចំណូលទទួលបានពីការអនុញ្ញាតអោយថតខ្សែភាពយន្ត |
| | | 7303 | ផលទុនពីសកម្មភាពទេសចរណ៍ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ |
| | | 7304 | ផលទុននៃសកម្មភាពវប្បធម៌ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ ព្រះបរមរាជវាំង ការអនុញ្ញាត អោយថតចំឡងបទចំរៀង.................... |
| | | 7305 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំណូលទទួលបានពីការផ្តល់សេវាផ្នែកបញ្ញើរសំបុត្រ ឬ ឥវ៉ាន់ និង ការប្រើប្រាស់ សេវាទូរគមនាគមន៍ |
| | | 7306 | ផលទុនពីវិទ្យុ ទូរទស្សន៍ | ចំណូលទទួលបានពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ និងវិទ្យុ |
| | | 7307 | ផលទុននៃសេវាផ្គត់ផ្គង់ទឹក | ចំណូលទទួលបានពីចំណែកគិតជាភាគរយនៃផលចំណេញលើសកម្មភាពផលិតទឹកស្អាត បង់ដោយរដ្ឋាករទឹក និង ផលពីសេវាផ្គត់ផ្គង់ទឹកផ្សេងទៀត |
| | | 7308 | ផលទុនផ្សេងៗទៀត | ចំណូលទទួលបានពីផលទុនផ្សេងៗទៀតរបស់ស្ថាប័នរដ្ឋ និង សហគ្រាសសាធារណៈ ក្រៅពីអនុគណនី ៧ ខាងលើ ដូចជាចំណូល ២ % លើផលិតផលស្រាបៀរអង្គរ ចំណូល ពីពាណិជ្ជសញ្ញា ចំណូលពីសេវាសោតទស្សន៍ ចំណូលពីការលក់ផលិតផលកសិកម្ម មានៈស្រូវពូជ ពោត សណ្តែក ពូជសត្វ កូនរុក្ខជាតិ............ |
| | 731 | | រដ្ឋបាល និងសេវា ( មិនរកចំណេញ ) | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិ និងសេវា នៃរដ្ឋបាលសាធារណៈ និង សិទ្ធរដ្ឋបាលផ្សេងទៀត |
| | | 7311 | ការលក់សំភារៈបរិក្ខារ សំភារៈខូចខាត និងសំភារៈសិក្សា | ចំណូលទទួលបានពីការលក់សំភារៈបរិក្ខារចាស់ៗដូចជា : រថយន្ត ម៉ូតូ កំព្យូទ័រ តុ ទូ...... |
| | | 7312 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | ចំណូលទទួលបានពីការលក់សៀវភៅការងារ ការលក់ឯកសារផ្សេងៗ និង លតាប័ត្រ របស់ពន្ធដារ និង គយ ចំណូលពីការចេញលិខិតបញ្ជាក់ពាក់ព័ន្ធបទល្មើសផ្សេងៗ ចំណូលពីការលក់ឯកសារដេញថ្លៃ.................... |
| | | 7313 | ផលនៃការដឹកជញ្ជូនទំនិញ | ចំណូលទទួលបានពីការផ្តល់សេវាដឹកជញ្ជូនទំនិញដោយរដ្ឋ |
| | | 7314 | ផលនៃប្រតិបត្តិការអន្តរាគមន៍ដើម្បីថែទាំកិច្ចដំណើរការ | |
| | | 7315 | កំរៃនៃការថែទាំ | ចំណូលទទួលបានពីការផ្តល់សេវាថែទាំ ដូចជា ចំណូល ១% បានពីការពិនិត្យ និង ព្យាបាលអ្នកជំងឺដោយមន្ទីរពេទ្យរដ្ឋ.................. |
| | | 7316 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទិចកំទីសត្វពាហនៈ | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី និង សត្វពាហនៈ |

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 7318 | ផលពីរដ្ឋបាល និង សេវាផ្សេងៗទៀត | ចំណូលទទួលបានពីផលនៃរដ្ឋបាល និង សេវាផ្សេងៗទៀតក្រៅពីអនុគណនី ០៦ ខាងលើ ដូចជា កំរៃសោងសង់ផ្លូវនៅតាមខេត្ត-ក្រុង ដែលបង់ដោយក្រុមហ៊ុនម៉ៅការ......... |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | ចំណូលទទួលបានពីស្ថាប័នរដ្ឋក្នុងការចេញលិខិតអនុញ្ញាតបើកបរ លិខិតឆ្លងដែន សោហ៊ុយយុត្តិធម៌ និង ចំណូលពីការចុះបញ្ជីគណៈបក្សនយោបាយ |
| | | 7321 | អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ) | ចំណូលទទួលបានពីការផ្តល់ទិដ្ឋាការ និង ការចេញលិខិតឆ្លងដែន |
| | | 7322 | ផលពីការចុះបញ្ជីគណៈបក្សនយោបាយ | ចំណូលទទួលបានពីការចុះបញ្ជីគណៈបក្សនយោបាយ |
| | | 7323 | ផលលើការបង្កើតសហគ្រាស | ចំណូលទទួលបានពីការចុះបញ្ជីធ្វើពាណិជ្ជកម្ម |
| | | 7324 | ផលពីការបង់សិទ្ធប្រឡង | ចំណូលទទួលបានពីភាគទានដែលបង់ដោយសិស្សដើម្បីទទួលបានសិទ្ធប្រឡង |
| | | 7325 | ផលពីការលក់ស្លាកលេខ | ចំណូលទទួលបានពីសេវាផ្តល់ស្លាកលេខ |
| | | 7326 | ចំណូលពីប្រដាប់ភ្លើ | ចំណូលទទួលបានពីការជំនុំជំរះក្តី |
| | | 7327 | សេវាសុរិយោដី និងសេវាសំណង់ | ចំណូលទទួលបានពីការចុះបញ្ជីក្បាលដី និងការចេញប្លង់កាន់កាប់ដីធ្លី ផ្ទះសម្បែង និងការអនុញ្ញាតអោយសាងសង់ |
| | | 7328 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ចំណូលទទួលបានពីការត្រួតពិនិត្យគុណភាពទំនិញ គុណភាពឱសថ កាសែត និងភាពយន្ត និង ការគោរពបទដ្ឋាន និង ចំណូលពីការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ការឃ្លាំមើលការអនុវត្តគំរោង........... |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈ ការជួលសំភារៈ-មធ្យោបាយដឹកជញ្ជូន ការជួលអចលនវត្ថុផ្សេងៗក្រៅពីដីធ្លី និងការប្រើប្រាស់សេវាបង្វែរដោយម្ចាស់កសិដ្ឋាន |
| | | 7331 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈនៅរដ្ឋបាលកណ្តាល |
| | | 7332 | ការជួលសហគ្រាសសាធារណៈនៅខេត្តក្រុង ( មន្ទីរជំនាញ ) | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈនៅតាមខេត្ត-ក្រុង |
| | | 7333 | ការជួលសំភារៈ និងមធ្យោបាយដឹកជញ្ជូន | ចំណូលទទួលបានពីការជួលសំភារៈ និង មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ |
| | | 7334 | ការជួលអចលនវត្ថុ ( អសង្ហារឹម ) | ចំណូលទទួលបានពីការជួលអាគារ ដូចជា រោងកុន ឃ្លាំង រោងមហោស្រព រោងជាង .. |
| | | 7335 | ចំណូលពីការប្រើប្រាស់សេវាបង្វែរដោយម្ចាស់កសិដ្ឋាន | ចំណូលត្រូវបានបង្វែរដោយកសិករដោយការប្រើប្រាស់សេវាដែលបានវិនិយោគដោយរដ្ឋ |
| **74** | | | **ផលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម** | **កត់ត្រាចំណូលពីការពិន័យ និង ការដាក់ទណ្ឌកម្មដែលត្រូវទូទាត់ទៅអោយរដ្ឋចំពោះបទល្មើស នឹងច្បាប់ ឬ បទបញ្ជារដ្ឋបាល ។ ការពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធ ដែលទាក់ទងនឹងពន្ធពិសេសមួយត្រូវបានចុះជាចំណូលក្នុងផ្នែកនេះ ប៉ុន្តែការដាក់ពិន័យ និង ការដាក់ទណ្ឌកម្មសារពើពន្ធផ្សេងៗទៀតត្រូវបានកត់ត្រា ក្នុងចំណូលសារពើពន្ធផ្សេងៗទៀត ។** |
| | 741 | | ផលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម | ចំណូលទទួលបានពីការពិន័យចំពោះការមិនអនុវត្តតាមកិច្ចសន្យានៃការជួលអាគារ ឬ ដីធ្លី ..... និង ចំណូលពីការត្រួតពិនិត្យដោយឆ្លក់រថយន្តលើសទំងន់ |

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| 75 | | | ការឧបត្ថម្ភ អំណោយ / | ការឧបត្ថម្ភ ឬ អំណោយអាចជាហិរញ្ញវត្ថុ ឬ សំភារៈ ។ ប្រសិនបើការឧបត្ថម្ភ ឬ អំណោយនេះ ពាក់ព័ន្ធនឹងចំណាយចរន្តត្រូវបានកត់ត្រាក្នុងជំពូកនេះ ផ្ទុយទៅវិញបើពាក់ព័ន្ធនឹងចំណាយវិនិយោគ ការឧបត្ថម្ភត្រូវកត់ត្រាក្នុងជំពូក ១៣ ។ ពាក្យឧបត្ថម្ភត្រូវបានប្រើប្រាស់សំរាប់ការបង្វែរធ្វើដោយរដ្ឋ ឬអង្គការអន្តរជាតិ រីឯអំណោយមានធម្មជាតិដូចគ្នានឹងការឧបត្ថម្ភ ប៉ុន្តែបានមកពីបុគ្គលឯកជន ( បុគ្គល ឬ សមាគម ) |
| | 751 | | ឧបត្ថម្ភកធនពីទ្វេភាគី | ចំណូលទទួលបានពីការឧបត្ថម្ភកធនពីប្រទេសនានា ដូចជា ជប៉ុន បារាំង........... |
| | | | ប្រទេស..... | |
| | 752 | | ឧបត្ថម្ភកធនពីពហុភាគី | ចំណូលទទួលបានពីការឧបត្ថម្ភដោយអង្គការអន្តរជាតិដូចជា : យូនីសេហ ធនាគារពិភពលោក.... |
| | 753 | | ជំនួយផ្សេងៗទៀត | ចំណូលទទួលបានពីជំនួយផ្សេងៗទៀតដែលមិននៅក្នុងគណនី ០២ ខាងលើ |
| 76 | | | **ផលហិរញ្ញវត្ថុ** | កត់ត្រាចំណូលទទួលបានពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដូចជា ការប្រាក់ទទួលបាន ចំណេញពីការប្តូរប្រាក់......... |
| | 761 | | ការប្រាក់នៃការអោយខ្ចី | ចំណូលជាការប្រាក់ពីការអោយខ្ចីនូវមូលធន |
| | 762 | | អន្តរការីយកម្មនៃទីផ្សារមូលប័ត្រ | ចំណូលទទួលបានពីការបង់ជាភាគរយដោយទីផ្សារមូលប័ត្រ |
| | 763 | | ភតិសន្យា | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនទិញសម្ភារៈ លើការទទួលបានលិខិតធានាដើម្បីខ្ចីលុយពីធនាគារ |
| | 764 | | អន្តរការីយកម្មនៃទីផ្សារអចលនវត្ថុ | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនអចលនទ្រព្យក្នុងការទិញ និងលក់អចលនទ្រព្យ |
| | 765 | | អន្តរការីយកម្មនៃទីផ្សារធានារ៉ាប់រង | ចំណូលទទួលបានពីការបង់ជាភាគរយនៃការលក់ប័ណ្ណធានារ៉ាប់រង |
| | 766 | | ចំណេញពីការប្តូរប្រាក់ | ចំណូលពីលំអៀងនៃការប្តូរប្រាក់ |
| | 768 | | ផលហិរញ្ញវត្ថុផ្សេងទៀត | ចំណូលពីការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងៗទៀតដែលមិនស្ថិតនៅក្នុងគណនី ០២ ខាងលើ |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | ត្រូវបានកត់ត្រានៅក្នុងជំពូកនេះនូវចំណែកមួយនៃចំណូលតាមដីកាដែលជាគំនិតផ្តួចផ្តើមរបស់រតនាគារជាតិ ឬ អាណាប័ក និង កត់ត្រាផងដែរនូវចំណូលពិតដែលបាន ពីការបោះផ្សាយប្រតិបត្តិការនៃការគ្រប់គ្រង ( កំរៃជើងសាររតនាគារ) ឬការប្រគល់អោយនូវសកម្មអចលកម្មហិរញ្ញវត្ថុ ឬ មិនហិរញ្ញវត្ថុ ។ |
| | 771 | | ផលផ្សេងៗ និងកិច្ចប្រតិបត្តិការគ្រប់គ្រង | ចំណូលទទួលបានពីសេវារតនាគារ និង អតិរេកថវិកាខេត្ត-ក្រុង |
| | | 7711 | ចំណូលពីការបង់អតិរេករបស់ថវិកាខេត្ត-ក្រុង | ចំណូលទទួលបានពីអតិរេកថវិកាខេត្ត-ក្រុង ក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ |
| | | 7712 | កំរៃរតនាគារ | ចំណូលទទួលបានពីការប្រើប្រាស់សេវារតនាគារក្នុងប្រតិបត្តិការបង្វែរសាច់ប្រាក់ ដូចជាការបង្វែរលើគណនីបញ្ញើរ......... |
| | | 7713 | ចំណូលពីអតិរេករបស់ថវិការដ្ឋ | ចំណូលទទួលបានពីលទ្ធផលនៃការអនុវត្តថវិការដ្ឋដែលបង្ហាញអំពីចំនួនលើសនៃចំណូលធៀបនឹងចំណាយក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ |

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាចរន្តរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | 772 | | ផលចែងពេជ្រនការបូបនីយកម្មសហគ្រាសសាធារណ: | ចំណូលទទួលបានពីការលក់សហគ្រាសសាធារណៈទៅអោយឯកជនកាន់កាប់ |
| | 775 | | ផលពីការលក់អចលនវត្ថុ | ចំណូលទទួលបានពីការលក់ផ្ដាច់ទ្រព្យសម្បត្តិអចលកម្មរបស់រដ្ឋ ដូចជា ដីធ្លី និង អាគារ និង ប្រាក់លំអៀងពីការដោះដូរទ្រព្យសម្បត្តិទាំងនោះ |
| | 778 | | ផលផ្សេងៗទៀត | ចំណូលទទួលបានពីការបង់ចូលថវិកាជាតិវិញនូវទឹកប្រាក់ដែលបានបើកផ្ដល់លើសលុយសល់ពីការអនុវត្តគំរោង ។ គណនីនេះកត់ត្រាផងដែរនូវការកែតំរូវលើការបិទការចំណាយដែលបង្វែរការចំណាយមួយនៃកិច្ចដំណើរការនៅផ្នែកវិនិយោគ គឺជាកិច្ចប្រតិបត្តិការថវិកាតាមជីកា |
| ក្រុមទី២: ចំណូលតាមជីកា | | | | ចំណូលមិនឆ្លងកាត់សាច់ប្រាក់ ។ |
| ប្រភេទទី៣: ចំណូលតាមជីកា (មិនឆ្លងកាត់សាច់ប្រាក់) | | | | ចំណូលមិនឆ្លងកាត់សាច់ប្រាក់ ។ ចំណូលនេះមានការងារនៃរដ្ឋទេយ្យ ។ |
| 78 | | | ការងារនៃរដ្ឋទេយ្យ | គណនីនេះត្រូវបានប្រើប្រាស់សំរាប់ផ្ទុំឡើងវិញក្នុងផ្នែកដំណើរការនូវទឹកប្រាក់បន្ទុកដែលគាំទ្រនៅក្នុងឆ្នាំនូវការងារដែលធ្វើដោយភ្នាក់ងាររបស់រដ្ឋហើយដែលមានលក្ខណៈជាការងារវិនិយោគ ។ នីតិវិធីនេះអនុញ្ញាតអោយលុបចោលនូវចំណាយដែលទូទាត់នៅគណនីនៃបន្ទុកថ្នាក់ ៦ ។ នៅទីបញ្ចប់ការចំណាយមួយត្រូវបានបញ្ចូលទៅក្នុងថ្នាក់ ២ ។ គឺជាប្រតិបត្តការថវិកាតាមជីកា ។ |
| ខ.សរុបចំណូលជាមូលធន (ក្រុមទី១+ក្រុមទី២) | | | | ចំណូលជាមូលធនប្រមូលផ្ដុំគណនីទាំងឡាយដែលទាក់ទងនឹងមូលនិធិផ្ទាល់ ការខ្ចី និង ចំណូលប្រហាក់ប្រហែល ។ ចំណូលនេះរួមមាន: ចំណូលពិត និង ចំណូលតាមជីកា |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | ចំណូលជាសាច់ប្រាក់ជាក់ស្ដែង ។ ចំណូលពិតរួមមាន : ចំណូលពីប្រភពផ្ទាល់ និង ចំណូលពីប្រភពខាងក្រៅ ។ |
| ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់ | | | | ចំណូលទទួលបានពីក្នុងប្រទេស ។ ចំណូលនេះមានអចលកម្មហិរញ្ញវត្ថុ ។ |
| 27 | | | អចលកម្មហិរញ្ញវត្ថុ | ចំណូលប្រភេទនេះរួមមាន: តំលៃដែលទទួលបានក្នុងក្របខ័ណ្ឌនៃការចល័តថវិកាដូចជាតំលៃដែលបានទទួលដោយការអោយខ្ចី ( ភាគហ៊ុន ឬ មូលប័ត្រ) |
| | 271 | | ការអោយខ្ចី ( ការសងវិញនូវមូលធន ) | ចំណូលដែលទទួលបានពីការសងវិញនូវទឹកប្រាក់កម្ចីបន្ត ដូចជាការសងវិញនូវទឹកប្រាក់កម្ចីបន្តពី រដ្ឋាករទឹក អគ្គិសនីកម្ពុជា............ |
| ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ | | | | ចំណូលទទួលបានពីក្រៅប្រទេស ។ ចំណូលនេះរួមមាន : ឧបត្ថម្ភធនវិនិយោគ និង ការខ្ចី និងចំណូលប្រហាក់ប្រហែល ។ |
| 13 | | | ឧបត្ថម្ភធនវិនិយោគ | ចំណូលទទួលបានពីការឧបត្ថម្ភសំរាប់ចូលរួមចំណែកក្នុងការវិនិយោគ |
| | 131 | | ឧបត្ថម្ភធនពីទ្វេភាគី | ចំណូលទទួលបានពីការឧបត្ថម្ភធនពីទ្វេភាគី |
| | | 1311 | ជប៉ុន | ចំណូលទទួលបានពីការឧបត្ថម្ភធនពីប្រទេសជប៉ុន |
| | | 1312 | បារាំង | ចំណូលទទួលបានពីការឧបត្ថម្ភធនពីប្រទេសបារាំង |
| | | 1313 | អាឡឺម៉ង់ | ចំណូលទទួលបានពីការឧបត្ថម្ភធនពីប្រទេសអាឡឺម៉ង់ |

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 1318 | ផ្សេងៗ | ចំណូលទទួលបានពីការឧបត្ថម្ភធនពីប្រទេសផ្សេងៗទៀតក្រៅពីអនុគណនី ០៣ ខាងលើ |
| | 132 | | ឧបត្ថម្ភធនពីពហុភាគី | ចំណូលទទួលបានពីការឧបត្ថម្ភធនពីពហុភាគី |
| | | 1321 | ធនាគារពិភពលោក | ចំណូលទទួលបានពីការឧបត្ថម្ភធនពីធនាគារពិភពលោក |
| | | 1322 | ធនាគារអភិវឌ្ឍន៍អាស៊ី | ចំណូលទទួលបានពីការឧបត្ថម្ភធនពីធនាគារអភិវឌ្ឍន៍អាស៊ី |
| | | 1323 | អង្គការអាយហ្វាត | ចំណូលទទួលបានពីការឧបត្ថម្ភធនពីអង្គការអាយហ្វាត |
| | | 1324 | អង្គការអូប៉ិច | ចំណូលទទួលបានពីការឧបត្ថម្ភធនពីអង្គការអូប៉ិច |
| | | 1328 | ផ្សេងៗ | ចំណូលទទួលបានពីការឧបត្ថម្ភធនពីអង្គការអន្តរជាតិផ្សេងៗទៀតក្រៅពី អនុគណនី ០៤ ខាងលើ |
| | 133 | | ឧបត្ថម្ភធនសំរាប់ការរំលស់បំណុល | ចំណូលទទួលបានពីការឧបត្ថម្ភធនផ្សេងៗទៀតសំរាប់ការរំលស់បំណុល |
| **16** | | | **ការខ្ចី និងបំណុលប្រហាក់ប្រហែល** | **កត់ត្រាចំណូលទទួលបានពីការខ្ចីក្នុងប្រទេស និង ក្រៅប្រទេស** |
| | 161 | | ការខ្ចីក្នុងប្រទេស | ចំណូលទទួលបានពីការខ្ចីក្នុងប្រទេស |
| | | 1611 | ធនាគារជាតិនៃកម្ពុជា | ចំណូលទទួលបានពីការខ្ចីពីធនាគារជាតិនៃកម្ពុជា |
| | | 1612 | ធនាគារពាណិជ្ជ | ចំណូលទទួលបានពីការខ្ចីពីធនាគារពាណិជ្ជ |
| | | 1618 | ផ្សេងៗ | ចំណូលទទួលបានពីការខ្ចីក្នុងប្រទេសផ្សេងៗទៀតក្រៅពីអនុគណនី ០២ ខាងលើ |
| | 162 | | ការខ្ចីក្រៅប្រទេសពីពហុភាគី | ចំណូលទទួលបានពីការខ្ចីក្រៅប្រទេសពីអង្គការអន្តរជាតិនានា ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការអាយហ្វាត.......... |
| | 163 | | ការខ្ចីក្រៅប្រទេសពីទ្វេភាគី | ចំណូលទទួលបានពីការខ្ចីក្រៅប្រទេសពីប្រទេសនានា ដូចជា ជប៉ុន បារាំង អាឡឺម៉ង់.... |
| | 165 | | បរិវិសករប័ណ្ណរតនាគារ | |
| | | 1651 | សន្ទឹកប័ណ្ណ | |
| | | 1652 | លើគណនីចរន្ត | |
| | 166 | | សញ្ញាប័ណ្ណ | ចំណូលទទួលបានពីការលក់មូលប័ត្រដែលបោះផ្សាយដោយរដ្ឋ |
| **ក្រុមទី២: ចំណូលតាមជីកា** | | | | **ចំណូលមិនទូទាត់សាច់ប្រាក់គឺជាតិចូលរួមចំណែកនៃការបង្វែរ ឬ ផ្ទេរធនធាន** |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | | សរុបរួមចំណាយថវិកាទូទៅរបស់រដ្ឋ (ក+ខ) | សរុបចំណាយប្រចាំ និង សរុបចំណាយជាមូលធន ៖ |
| | | | ក.សរុបចំណាយចរន្ត (ក្រុមទី ១+ក្រុមទី ២) | ចំណាយជាប្រចាំដែលប្រមូលផ្តុំនូវគណនីទាំងឡាយសំរាប់កត់ត្រារាល់បន្ទុកតាមប្រភេទនីមួយៗ ក្នុងនោះមាន: ចំណាយពិត ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក ៖ |
| | | | ក្រុមទី១: ចំណាយពិត | ចំណាយជាសាច់ប្រាក់ជាក់ស្តែង ដែលរួមមាន: ចំណាយមធ្យោបាយសេវា បន្ទុកហិរញ្ញវត្ថុ អន្តរាគមន៍សាធារណៈ ចំណាយផ្សេងៗ និង ការសងនិងការបង្វិលចំណូល |
| | | | ប្រភេទទី១: មធ្យោបាយសេវា | ចំណាយដើម្បីទទួលបាននូវមធ្យោបាយ និង សេវាផ្សេងៗ ដែលរួមមាន : ការទិញ សេវាខាងក្រៅ សេវាខាងក្រៅផ្សេងៗ និង បន្ទុកបុគ្គលិក ៖ |
| 60 | | | ការទិញ | កត់ត្រាចំណាយលើការទិញសំភារៈសំរាប់ការងារថែទាំទាំងឡាយដែលធ្វើដោយរដ្ឋ សំភារៈផ្គត់ផ្គង់រដ្ឋបាល ស្បៀងអាហារ សំលៀកបំពាក់ និង ការតុបតែង និង ចំណាយលើការប្រើប្រាស់ថាមពល និង ទឹក ។ |
| | 601 | | សំភារៈផ្គត់ផ្គង់ថែទាំ | ចំណាយលើសំភារៈផ្គត់ផ្គង់ ប្រេងឥន្ធនៈ និង ប្រេងរំអិល ដែលពាក់ព័ន្ធនឹង ការងារថែទាំ និង ជួសជុលទ្រព្យសម្ភារីម និង អសម្ភារីម |
| | | 6011 | សំភារៈផ្គត់ផ្គង់ សំអាត និងអនាម័យ | ចំណាយលើការទិញសំភារៈប្រើប្រាស់សំរាប់សំអាត និង អនាម័យ ដូចជា អ្វសាវែល សាប៊ូ ថ្នាំបាញ់កញ្ចក់ ក្រដាស់អនាម័យ ថ្នាំបាញ់បន្ទប់ ច្រាស់ កន្សែងដៃ ថ្នាំបាញ់មូស ។ ល ។ |
| | | 6012 | សំភារៈផ្គត់ផ្គង់ សំរាប់ថែទាំអាគារ និងប្រាសាទ | ចំណាយលើការទិញសំភារៈសំរាប់ជួសជុល ថែទាំ អាគារ របងអាគារធ្វើការ រៀបចំសួនច្បារ និង ប្រាសាទ |
| | | 6013 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | ចំណាយលើការទិញសំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ស្ពាន លូ ដែលការងារថែទាំនេះ ធ្វើដោយ មន្ត្រីរបស់រដ្ឋ ដូចជាចំណាយលើការទិញម្នាងសិលា ខ្សាច់ម៉ត់ ខ្សាច់គ្រាប់ ស៊ីម៉ង់ត៍ គ្រួស............. |
| | | 6014 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ | ចំណាយលើការទិញសំភារៈជួសជុលថែទាំឧបករណ៍ដូចក្នុងគណនី ៦០៥ ២១៥ ២១៧ ២១៨ ដូចជាកង់ឡាន កង់ម៉ូតូ ប៊ូស៊ី........ |
| | | 6015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | ចំណាយលើការទិញប្រេងឥន្ធនៈ និង ប្រេងរំអិលសំរាប់ថែទាំយានយន្ត និង សំរាប់បំរើអោយការងាររដ្ឋបាល |
| | | 6018 | ផ្សេងៗ | ចំណាយលើការទិញសំភារៈថែទាំទ្រព្យសម្ភារីម និង អសម្ភារីម ដែលមិនមាននៅក្នុងអនុគណនី ០៥ ខាងលើ (៦០១១, ៦០១២, ៦០១៣, ៦០១៤, និង ៦០១៥) |
| | 602 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | ចំណាយលើការទិញសំភារៈតូចតាចដូចជាសំភារៈការិយាល័យ ការបោះពុម្ព សៀវភៅមើល និង ឯកសារផ្សេងៗ សំរាប់ដំណើរការរដ្ឋបាល ។ |
| | | 6021 | សំភារៈការិយាល័យ និងការបោះពុម្ព | ចំណាយលើការទិញសំភារៈការិយាល័យ និង បោះពុម្ព ដូចជា ក្រដាសរ៉ាម ខ្មៅដៃ ប៊ិច ហ្វឺត ស៊ីមី និង បោះពុម្ពតែមទិដ្ឋាការ លិខិតប័ត្រ ....... |
| | | 6022 | សៀវភៅមើល និងឯកសារ | ចំណាយលើការទិញសៀវភៅមើល និង ឯកសារផ្សេងៗ ដូចជាសៀវភៅថវិកា វចនានុក្រម សៀវភៅធម៌ សៀវភៅរបស់ក្រសួងអប់រំដែលបំរើឱ្យការងាររដ្ឋបាល |
| | | 6028 | ផ្សេងៗ | ចំណាយលើការទិញសំភារៈផ្គត់ផ្គង់រដ្ឋបាលដ៏ទៃទៀតដែលមិនមាននៅក្នុងអនុគណនីពីរខាងលើ ( ៦០២១ និង ៦០២២) |

# មាតិកាចំណាយថវិកាចរន្តរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | 603 | | ស្បៀងអាហារ និងផលិតផលកសិកម្ម | ចំណាយលើការទិញអាហារ និងភេសជ្ជៈសំរាប់រដ្ឋបាលក្រៅពីការទទួលភ្ញៀវ និង ការប្រជុំ ក្នុងគណនី ៦២២ និងចំណាយលើការទិញផលិតផលចាំបាច់សំរាប់សកម្មភាពកសិកម្ម ជូនក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល និង អប់រំ................. |
| | | 6031 | ស្បៀង | ចំណាយលើការទិញផ្លែឈើ ទឹក នំ ភេសជ្ជៈ សំរាប់រដ្ឋបាល និង ទិញអង្ករបស់ក្រសួងការពារជាតិ និង មហាផ្ទៃ ។ |
| | | 6032 | ចំណីសត្វ | ចំណាយលើការទិញស្មៅក្រៀម និង ចំណីសត្វផ្សេងៗ |
| | | 6033 | ពូជ និងកូនរុក្ខជាតិ | ចំណាយលើការទិញគ្រាប់ពូជសំរាប់កសិដ្ឋាន កូនឈើ និង ដើមផ្កាសំរាប់លំអសួន |
| | | 6034 | ផលិតផលការពារសុខមាលភាពរុក្ខជាតិ និងជី | ចំណាយលើការទិញផលិតផលដើម្បីការពាររុក្ខជាតិ ដូចជាថ្នាំសំលាប់សត្វល្អិត ជី... |
| | | 6035 | ពូជសត្វ ឱសថ និងវត្ថុធាតុសំរាប់បសុពេទ្យ | ចំណាយលើការទិញពូជសត្វ និង ផលិតផល ដូចជា ឱសថ និង វត្ថុធាតុសំរាប់ព្យាបាលសត្វ |
| | | 6038 | ផ្សេងៗ | ចំណាយលើការទិញស្បៀងអាហារ និង ផលិតផលកសិកម្មដទៃទៀតដែលមិនមាននៅក្នុងអនុគណនី ៥ ខាងលើ ( ៦០៣១, ៦០៣២, ៦០៣៣, ៦០៣៤, និង ៦០៣៥) |
| | 604 | | សំលៀកបំពាក់ និងការតុបតែង | ចំណាយលើការផ្គត់ផ្គង់ឯកសណ្ឋាន សំលៀកបំពាក់ការពារសុវត្ថិភាព មេដាយ សញ្ញាសក្តិ និង គ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ជូនមន្ត្រីមានសមត្ថកិច្ច និង មន្ត្រីរាជការដែលត្រូវអោយមានឯកសណ្ឋានតាមច្បាប់កំណត់ ។ |
| | | 6041 | ឯកសណ្ឋាន | ចំណាយលើការផ្គត់ផ្គង់ឯកសណ្ឋាន ជូនមន្ត្រីមានសមត្ថកិច្ច និង មន្ត្រីរាជការដែលត្រូវអោយមាន ឯកសណ្ឋានតាមរដ្ឋកំណត់ ដោយរួមទាំងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ ដូចជា មួក សញ្ញាសក្ត......។ |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព | ចំណាយលើការទិញសំលៀកបំពាក់ការពារសុវត្ថិភាពជូនមន្ត្រីមានសមត្ថកិច្ច និង មន្ត្រីរាជការក្នុងពេលបំពេញការងារ ដូចជាស្បែកជើងសុវត្ថិភាព មួកសំរាប់អ្នកធ្វើការនៅការដ្ឋានសំណង់..... |
| | | 6043 | មេដាយ ( គ្រឿងឥស្សរិយយស) | ចំណាយលើការផ្គត់ផ្គង់មេដាយ ( គ្រឿងឥស្សរិយស) ជូនមន្ត្រីមានសមត្ថកិច្ច និង មន្ត្រីរាជការដែលបំពេញការងារបានល្អ ។ |
| | | 6048 | ផ្សេងៗ | ចំណាយលើការផ្គត់ផ្គង់សំលៀកបំពាក់ និង ការតុបតែងផ្សេងៗទៀតដែលមិនមាននៅក្នុងអនុគណនី ០៣ ខាងលើ ( ៦០៤១, ៦០៤២ និង ៦០៤៣) ។ |
| | 605 | | សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ | ចំណាយលើការទិញសំភារៈគ្រប់ប្រភេទ ដូចជាសំភារៈតូចតាចសំរាប់ប្រើប្រាស់ និង សំភារៈបរិក្ខារបច្ចេកទេស សំភារៈ-ឧបករណ៍ដឹកជញ្ជូន សង្ហារឹម.... ដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយជាមូលធន |
| | | 6051 | សំភារៈ និងបរិក្ខារបច្ចេកទេស | ចំណាយលើការទិញសំភារៈ និង បរិក្ខាបច្ចេកទេស ដូចជា កំព្យូទ័រ ព្រីនធ័រ មាស៊ីនថតចម្លង ទូរស័ព្ទ ជំរងអគ្គី របាំងការពារផ្សេង ទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង បំពង់ពន្លត់អគ្គិភ័យ អាគុយ............... |
| | | 6052 | សង្ហារឹម | ចំណាយលើការទិញគ្រឿងសង្ហារឹម ដូចជា តុ ទូដាក់ឯកសារ សាឡុង កៅអី............ |
| | | 6053 | សំភារៈប្រើប្រាស់ | ចំណាយលើការទិញសំភារៈប្រើប្រាស់ ដូចជាសំភារៈកីឡាគ្រប់ប្រភេទ ថ្មពិលគ្រប់ប្រភេទ ហ្វីលថត កាសែតថតសំឡេង កាសែតវីដេអូ ញញួរ សោរចាក់ ម៉ាស៊ីនចោះ ឬ ខ្ទង់ ម៉ាស៊ីនខាត់ចប ឥដ្ឋកៅស៊ូ រណា........... |

## ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាចរន្តរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | ចរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 6151 | ការថែទាំ ដីធ្លី ព្រៃឈើ និងតំបន់ឆ្នេរ | ចំណាយលើការថែទាំ ដីធ្លី ព្រៃឈើ និង តំបន់ឆ្នេរ ដូចជា ចំណាយលើការកាប់ឆ្ការព្រៃ ភ្ជួររាស់ដី ចាក់ដីបំពេញ សោហ៊ុយវាស់វែងដីធ្វើប្លង់ ការស្តារស្រះ ត្រពាំង បឹងបួរ ទន្លេ........ |
| | | 6152 | ការថែទាំ ជួសជុលអាគារ និងប្រាសាទ | ចំណាយលើការថែទាំ ជួសជុលអាគារ និង ប្រាសាទ ដូចជាចំណាយលើការងារលាបថ្នាំ ការរៀបចំបណ្តាញអគ្គិសនីឡើងវិញដែលបណ្តាលមកពីការជួសជុលអាគារ និង ការជួសជុលរបងអាគារដែលជួលជាងពីក្រៅ............... |
| | | 6153 | ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | ចំណាយលើការងារថែទាំ និង ជួសជុលផ្លូវ ស្ពាន និង លូ ដូចជាចំណាយលើការលុបសំបុកមាន់ ជួសជុលផ្លូវ ជួសជុលប្រឡាយឡើងវិញ ប្តូរផ្ទាំងបាណ្ឌដែលឆេះខូច ជួសជុលស្ពាន ស្តារលូ និង ចំណាយប្រេងឥន្ធនៈ ដែលបំរើអោយការងារថែទាំ និង ជួសជុលនេះ................ |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ | ចំណាយលើការងារជួសជុលថែទាំគ្រប់ប្រព័ន្ធបណ្តាញទាំងអស់ដែលមិនមែនជាផ្លូវចរាចរ ដូចជា បណ្តាញទឹកស្អាត វារីអគ្គិសនិ ជួសជុលម៉ាស៊ីនត្រជាក់ តបណ្តាញអគ្គិសនីដែលមិនជាប់ពាក់ព័ន្ធ នឹងការជួសជុលអាគារ.................. |
| | | 6155 | ការថែទាំដែនទេសាទ | ចំណាយលើការងារថែទាំតំបន់នេសាទ ដូចជាការសំអាតត្រពាំង បឹង........ |
| | | 6156 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | ពាក់ព័ន្ធនឹងការងារថែទាំយានយន្ត ( សោហ៊ុយយានដ្ឋាន ) |
| | | 6157 | ការថែទាំ និងជួសជុលសំភារៈឧបករណ៍ការិយាល័យ-សំភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ចំណាយលើការជួសជុល និង ថែទាំសំភារៈឧបករណ៍ការិយាល័យ សំភារៈព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ដូចជា ម៉ាស៊ីនថតចំលង ទូរស័ព្ទ ម៉ាស៊ីនហ្វាក់ កំព្យូទ័រ... |
| | | 6158 | ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស | ចំណាយលើការថែទាំ និង ជួសជុលសំភារៈឧបករណ៍បច្ចេកទេសដទៃទៀត ដែលមិនមាននៅក្នុងអនុគណនី ០៧ ខាងលើ ( ៦១៥១, ៦១៥២, ៦១៥៣, ៦១៥៤, ៦១៥៥, ៦១៥៦ និង ៦១៥៧) |
| | 616 | | សោហ៊ុយធានារ៉ាប់រង | សោហ៊ុយធានារ៉ាប់រង ដូចជាអាគារ យានយន្ត.......... |
| | 617 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធ | ចំណាយលើការសិក្សាពិសោធន៍ និង ចំណាយលើសោហ៊ុយ ដើម្បីទទួលបាននូវការប្រើប្រាស់សេវា និង សិទ្ធិ ដែលមិនទាក់ទងនឹងការងារវិនិយោគ |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ | ចំណាយលើសោហ៊ុយសិក្សាពិសោធន៍ ដូចជាការសិក្សាលើប្រជាសាស្ត្រ សិក្សាពីតំរូវការ ការជួលម៉ូដែលសំរាប់សិក្សាស្រាវជ្រាវ ។ល។ |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា | ចំណាយលើការបង់សោហ៊ុយផ្សេងៗដើម្បីទទួលបាននូវការប្រើប្រាស់សេវា ដូចជា ចំណាយលើការជួលមេធាវី ភ្នាក់ងារអចលកម្ម............ |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ចំណាយលើការបង់សោហ៊ុយផ្សេងៗដើម្បីទទួលបាននូវការប្រើប្រាស់សិទ្ធិ ដូចជា ការចំណាយដើម្បីទទួលបាននូវសិទ្ធិថតចំលង និង ផ្សព្វផ្សាយ ការបង់សេវាដើម្បីទទួលបានសិទ្ធប្រើប្រាស់ផ្នែកព័ត៌មានវិទ្យា.................. |
| | | 6174 | សំណងផ្នែកស៊ីវិល | ចំណាយឧបត្ថម្ភជាប្រាក់គោលនយោបាយដល់ប្រជាជនជាថ្នូរដល់ការដកហូតដីធ្លី ឬផ្ទះសម្បែងទុកជាទ្រព្យសម្បត្តិរដ្ឋ ដើម្បីជាគុណប្រយោជន៍សាធារណៈ |
| | 618 | | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយដឹកជញ្ជូនដែលផ្តល់ដោយសហគ្រាស និង ក្រុមហ៊ុនឯកជនជានីតិបុគ្គល និង រូបវន្តបុគ្គល |
| | | 6181 | សំភារៈ និងទំនិញ | ចំណាយលើការដឹកជញ្ជូនសំភារៈ និង ទំនិញ ដូចជាការដឹកជញ្ជូនហីបកាទូត កេសទំនិញ ថ្នាំពេទ្យ.......... |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាចរន្តរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| 62 | | | សេវាខាងក្រៅផ្សេងៗ | ជំពូកនេះ កត់ត្រានូវចំណាយលើសេវាពីខាងក្រៅផ្សេងៗទៀត ក្រៅពីជំពូក ៦១ |
| | 621 | | បុគ្គលិកខាងក្រៅ | ចំណាយលើការជួលបុគ្គលិកពីខាងក្រៅដែលមិនមែនជាមន្ត្រីរាជការ |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | ចំណាយលើការជួលទីប្រឹក្សា និង អ្នកជំនួយការជាជនជាតិខ្មែរ និង បុគ្គលិកជាប់កិច្ចសន្យា ដែលរើសដោយក្រសួង-ស្ថាប័នផ្ទាល់ |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | ចំណាយលើជួលទីប្រឹក្សា និង អ្នកជំនួយការជាជនជាតិបរទេស |
| | | 6213 | បុគ្គលិក-សមូហភាពសាធារណៈផ្សេងៗ | ចំណាយលើបុគ្គលិក-សមូហភាពសាធារណៈផ្សេងៗទៀតដែលមិនមែនជាមន្ត្រីរាជការ ដូចជាចំណាយលើបុគ្គលិកយាំដែលដឹកក្មេងៗទៅសាលា សហគមភូមិឃុំ............ |
| | 622 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | ចំណាយលើសោហ៊ុយទទួលភ្ញៀវ ប្រជុំ សិក្ខាសាលា សន្និសីទ ពិធីបុណ្យ ពិធីតាំងពិពណ៌ក្នុង និង ក្រៅប្រទេស ឃោសនា និង ផ្សព្វផ្សាយព័ត៌សាធារណៈ និង ចំណាយលើការទិញវត្ថុ អនុស្សាវរីយ៍សំរាប់ជូន ភ្ញៀវនៅក្នុង និង ក្រៅប្រទេស |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ | ចំណាយលើការទទួលភ្ញៀវជាតិ ដូចជាភេសជ្ជៈ (តែ កាហ្វេ ទឹកក្រូច ស្ករ នំ ផ្លែឈើ.........) និង ចំណាយផ្សេងៗទៀតដែលទាក់ទងនឹងការរៀបចំពិធីជប់លៀងក្នុងការទទួលភ្ញៀវ...... |
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស | ចំណាយលើការទទួលភ្ញៀវបរទេស ដូចជាភេសជ្ជៈ (តែ កាហ្វេ ទឹកក្រូច ស្ករ នំ ផ្លែឈើ.....) និង ចំណាយផ្សេងៗទៀតដែលទាក់ទងនឹងការរៀបចំពិធីជប់លៀងក្នុងការទទួលភ្ញៀវ...... |
| | | 6223 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | ចំណាយលើការប្រជុំ សម្ពោធសមិទ្ធិផល សន្និសីទ សន្និបាត ការបណ្ដុះបណ្ដាលរយៈពេលខ្លី ដោយផ្ទាល់ និង ដោយប្រយោលលើកលែងតែចំណាយទូទាត់សោហ៊ុយក្នុងប្រទេសដែលមាន នៅក្នុងគណនី ៦២៤ និង ការទិញដែលពាក់ព័ន្ធនឹងជំពូក ៦០។ ចំណាយទាំងនោះមានដូចជា ចំណាយលើការជួលសាលប្រជុំ ទទួលបដិសណ្ឋារកិច្ច ពិធីការ អ្នកបកប្រែ រៀបចំហ្វុង តុបតែងសាល រៀបចំបដា ជួលអិលស៊ីឌី ជួលកំព្យូទ័រ ជួលម៉ាស៊ីនហ្វូតូកូពី និងចំណាយផ្សេងៗ ទៀតដែលទាក់ទងនឹងការរៀបចំពិធីជប់លៀង.......... |
| | | 6224 | សោហ៊ុយពិធីបុណ្យ | ចំណាយលើការរៀបចំពិធីបុណ្យជាតិ បុណ្យប្រពៃណី បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ បុណ្យរុក្ខទិវា និង ពិធីបុណ្យផ្សេងៗទៀត |
| | | | ▪ បុណ្យជាតិ និងបុណ្យប្រពៃណី | ចំណាយលើការរៀបចំពិធីបុណ្យជាតិ និង បុណ្យប្រពៃណី |
| | | | ▪ បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ | ចំណាយលើការរៀបចំពិធីបុណ្យចំរើនព្រះជន្មាយុព្រះមហាវីរៈក្សត្រ និង ព្រះរាជអគ្គមហេសី និង បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ |
| | | | ▪ បុណ្យរុក្ខទិវា | ចំណាយលើការរៀបចំពិធីបុណ្យរុក្ខទិវា |
| | | | ▪ បុណ្យផ្សេងៗទៀត | ចំណាយលើការរៀបចំពិធីបុណ្យផ្សេងៗទៀត |
| | | 6225 | ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | ចំណាយលើការទិញវត្ថុអនុស្សាវរីយ៍សំរាប់ជូនភ្ញៀវក្នុង និង ក្រៅប្រទេស ដែលទាក់ទងនឹង ការទទួល ភ្ញៀវ ការចូលរួមប្រជុំក្រៅប្រទេស ការបណ្ដុះបណ្ដាលក្រៅប្រទេស ការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និង សន្និសីទផ្សេងៗ ដូចជាការចំណាយលើការទិញកាបូប ដាក់ឯកសារមានសរសេរខ្លឹមសារសន្និបាត កាដូរគ្រប់ប្រភេទ................ |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

( ភ្ជាប់ជាមួយប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ )

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 6226 | សោហ៊ុយសំរាប់ការតាំងពិព័ណនៅក្នុង និងក្រៅប្រទេស | ចំណាយគ្រប់ប្រភេទលើការរៀបចំតាំងពិពណ៌នៅក្នុង និង ក្រៅប្រទេស ដោយផ្ទាល់ និង ដោយប្រយោល លើកលែងតែសោហ៊ុយបេសកកម្ម ការស្នាក់នៅ និង ហូបចុករបស់មន្ត្រីដែលត្រូវទៅចូលរួមរៀបចំពិធី ។ |
| | | 6227 | ការឃោសនា និងផ្សព្វផ្សាយពត៌មានសាធារណៈ | ចំណាយលើសោហ៊ុយសំរាប់ការផ្សព្វផ្សាយព័ត៌មានសាធារណៈផ្ទាល់ ដូចជា ផ្ទាំងប៉ាណូនៅព្រលានយន្តហោះ ផ្ទាំងពត៌មានសំរាប់ផ្សព្វផ្សាយពីសុខភាព ការរៀបចំស្បតផ្សព្វផ្សាយតាមទូរទស្សន៍................. |
| | 623 | | សោហ៊ុយជាវសារព័ត៌មាន និងឯកសារ | ចំណាយលើការជាវសារព័ត៌មាន និង ទស្សនាវដ្តីប្រចាំថ្ងៃ រាជកិច្ច និង សៀវភៅ និង ឯកសារផ្សេងៗទៀត ដែលមិនមាននៅក្នុងអនុគណនី ៦០២២ |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | ចំណាយលើប្រាក់បេសកកម្ម និង សោហ៊ុយធ្វើដំណើរ និង ស្នាក់នៅ របស់មន្ត្រីរាជការដែលត្រូវបំពេញបេសកកម្មក្នុងប្រទេស ដោយយោងលើអនុក្រឹត្យលេខ ១០ |
| | | 6241 | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយធ្វើដំណើរសំរាប់ចុះបំពេញបេសកកម្មក្នុងប្រទេស ដូចជាទិញសំបុត្រឡានយន្តហោះ កប៉ាល់ បង់ពន្ធព្រលាន................... |
| | | 6242 | សោហ៊ុយបេសកកម្ម | ចំណាយលើរបបប្រាក់បេសកកម្មក្នុងប្រទេស |
| | | 6243 | សោហ៊ុយស្នាក់នៅ | ចំណាយលើការស្នាក់នៅ និង ហូបចុក របស់មន្ត្រីរាជការដែលត្រូវចុះបេសកកម្មក្នុងប្រទេស |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | ចំណាយលើប្រាក់បេសកកម្ម និង សោហ៊ុយធ្វើដំណើរ និង ស្នាក់នៅ របស់មន្ត្រីរាជការដែលត្រូវបំពេញបេសកកម្មក្រៅប្រទេស ដោយយោងលើអនុក្រឹត្យលេខ ១០ |
| | | 6251 | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយធ្វើដំណើរសំរាប់ចុះបំពេញបេសកកម្មក្រៅប្រទេស ដូចជាទិញសំបុត្រឡាន យន្តហោះ កប៉ាល់ បង់ពន្ធព្រលាន................... |
| | | 6252 | សោហ៊ុយបេសកកម្ម | ចំណាយលើរបបប្រាក់បេសកកម្មក្រៅប្រទេស |
| | | 6253 | សោហ៊ុយស្នាក់នៅ | ចំណាយលើការស្នាក់នៅ និង ហូបចុក របស់មន្ត្រីរាជការដែលត្រូវចុះបេសកកម្មក្រៅប្រទេស |
| | 626 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំណាយលើការផ្ញើឯកសារ និង ទំនិញផ្សេងៗតាមប្រៃសណីយ៍ និង ចំណាយលើការប្រើប្រាស់សេវាទូរស័ព្ទ ទូរសារ និង សេវាអ៊ីនធឺណិត.... |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ | ចំណាយលើសោហ៊ុយប្រៃសណីយ៍ ដូចជាការផ្ញើរឯកសារ កញ្ចប់ឥវ៉ាន់...... |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ | ចំណាយលើសោហ៊ុយទូរគមនាគមន៍ ដូចជាការប្រើប្រាស់សេវាទូរស័ព្ទ ទូរសារ និង ការប្រើប្រាស់ សេវាអ៊ីនធឺណិត........ |
| | 627 | | សោហ៊ុយធនាគារ | ចំណាយលើសោហ៊ុយសំរាប់សេវាធនាគារជាតិ ធនាគារពាណិជ្ជកម្ម ដូចជា សោហ៊ុយលើការបង់ចំណូលជាមូលប័ត្រ កំរៃជើងសារលើការទិញមូលប័ត្រ និង ភាគហ៊ុន............ |
| | 628 | | សោហ៊ុយផ្សេងៗ | ចំណាយលើសេវាពីខាងក្រៅផ្សេងៗទៀតដែលមិនមាននៅក្នុងគណនីទាំង ០៧ ខាងលើ (៦២១, ៦២២, ៦២៣, ៦២៤, ៦២៥, ៦២៦ និង ៦២៧) |
